ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៥១/១១-ហ្រ្គេត អនធើរ ថេកស្ទាយ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: ម៉ារ សំបូរណា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: ស៊ីន គីមស៊ាន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន ហ្រ្គេត អនធើរ ថេកស្ទាយ ហ្វេកធើរី លីមីធីត
អាសយដ្ឋាន ៖ ភូមិលេខ ៤ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០៦៧ ៨៩៣ ៨៨៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក ជា លីឆាយ | ប្រធានរដ្ឋបាល |
| ២- លោក សុខ គង់ | ជំនួយការរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ហ្រ្គេត អនធើរ
- សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)

អាសយដ្ឋាន ៖ ភូមិលេខ ៤ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១២ ៨៨៥ ១១៥ ទូរសារ ៖ គ្មាន


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងភាគីកម្មករនិយោជិតៈ

១- លោក ផល វិនន័រ — មន្ត្រីសម្ព័ន្ធសហជីពស៊ីខៅឌូ

២- លោក អ៊ុន សុខវិទ្ធិ — ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ

៣- កញ្ញា ទ្រី សុខនីម — លេខាធិការសហជីព

៤- កញ្ញា សាន ស៊ីណា — សកម្មជន

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មការិនីផ្នែកប៉ះទាមទារតំឡើងតម្លៃឡូតិ៍ តម្លៃដើម ០.៣០ ដុល្លារអាមេរិក លេខកូដ ១០០១៣ ដល់តម្លៃ ០.៦០ ដុល្លារអាមេរិកក្នុងមួយឡូតិ៍។ និយោជកមិនឯកភាព គឺតំឡើងតម្លៃត្រឹមតែ ០.០៥ ដុល្លារអាមេរិក ក្នុងមួយឡូតិ៍ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៥៥៨/១១ កប/កណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី** ៖

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាលបានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ស្តីពីការកែលំអរលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ដោយមានការទាមទារចំនួន០១ចំណុច។ បន្ទាប់ពីទទួលបានពាក្យបណ្តឹងនេះរួចមក មន្ទីរការងារ និង

បណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាលបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារក្នុងសំណុំរឿងនេះ ដោយធ្វើការផ្សះផ្សានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ប៉ុន្តែមិនបានទទួលលទ្ធផលសះជានឹងគ្នាទេ ។ ចំណុចមិនសះជាចំនួន ០១ចំណុចនៅក្នុងសំណុំរឿងនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៥៥៨ កប/កណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក តាមលិខិតលេខ ៨៤១ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ និងភាគីកម្មករនិយោជិត តាមលិខិតលេខ ៨៤២ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាក្នុងសំណុំរឿងនេះ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានក្នុងថ្ងៃសវនាការ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការផ្សះផ្សា និងបានព្យាយាមសួររកនូវព័ត៌មានផ្សេងៗបន្ថែមទៀត ដែលទាក់ទងទៅនឹងមិនសះជាចំនួនសរុប ០១ ចំណុចនេះ តែមិនបានទទួលលទ្ធផលសះជាឡើយ។ សេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវចេញនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ប៉ុន្តែភាគីទាំងពីរបានឯកភាពគ្នាពន្យាការចេញសេចក្ដីបង្គាប់នេះ រហូតដល់ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្ដីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងបែងចែកសេចក្ដីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីផលប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្ដឹងជំទាស់លើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល លើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្ដីសម្រេចនេះ ជាសេចក្ដីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្ដឹងជំទាស់ទៅលើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើវិវាទអំពីផលប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្ដីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីផលប្រយោជន៍។ ការប្ដឹងជំទាស់របស់ភាគីទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើចំណុចវិវាទអំពីផលប្រយោជន៍ នឹងមិនបណ្ដាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្ដីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្ដីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទទាំងអស់ ដែលមាននៅក្នុងសំណុំរឿងនេះ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ឧត្ថម្ភ ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ហ្វ្រេត អននើរ ជូនលោក ជា លីឆាយ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០១១។

២- សារណាសង្ខេបទាក់ទងចំណុចវិវាទរបស់ក្រុមហ៊ុន ហ្វ្រេត អននើរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ ។

៣- លក្ខន្តិកៈក្រុមហ៊ុន ហ្វ្រេត អននើរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ។

៤- តារាងប្រាក់ឈ្នួលប្រចាំខែតុលា ឆ្នាំ២០១១ ។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន វ៉ុនឈើ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ។

៦- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ហ្វ្រេត អននើរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ។

៧- បញ្ជីឈ្មោះកម្មករផ្នែកប៉ះ ២៩.១១.២០១១។

៨- កាតការងាររបស់កម្មករឈ្មោះ នៅ ស៊ីថា, ប៉ែន នី , ព្រំ ខេន, យឹម សុភាព និង ណិប សម្ផស្ស។

៩- តារាងប្រាក់ឈ្នួលប្រចាំខែ វិច្ឆិកា ឆ្នាំ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្វ្រេត អននើរ លេខ ៥៥៨/១១ កប/កណ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ្វ្រេត អននើរ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៨៤១ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៨៤២ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៣- កិច្ចព្រមព្រៀងលើសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក

THE ARBITRATION COUNCIL

- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ប្រេ្គត អននើរ ផេកស្តាយ ហ្វេកធើរី លីមីតធីត ជាក្រុមហ៊ុនផលិតផលសំលៀកបំពាក់។ ក្រុមហ៊ុននេះ ទើបតែដូរឈ្មោះពីក្រុមហ៊ុន វីនណឹ ដែលមានកម្មករនិយោជិតចំនួនសរុបប្រហែល ១៩២០ នាក់។
- នៅក្នុងសំណុំរឿងនេះ ក្រុមហ៊ុន ប្រេ្គត អននើរ ផេកស្តាយ ហ្វេកធើរី លីមីតធីត គឺជាដើមបណ្តឹង ហើយសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ គឺជាចុងចំលើយ។ សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នេះមានសមាជិក ដែលជាកម្មករនិយោជិតនៅក្រុមហ៊ុន ប្រេ្គត អននើរ ផេកស្តាយ ហ្វេកធើរី លីមីតធីត ចំនួនប្រហែលជា ៩៣០ នាក់។ សហជីពនេះ ពុំទាន់មានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុននៅឡើយ ទេ។
- ក្រោយពីស្តាប់ភាគីវិវាទទាំងពីរ ក្រុមអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទដែលទាមទារ ដោយកម្មការិនីផ្នែកប៉ះឱ្យតំឡើងតម្លៃឡូតិ៍ដើម ០.៣០ ដុល្លារអាមេរិក ដែលមានលេខកូដ១០០១៣ ទៅតម្លៃ ០.៦០ដុល្លារអាមេរិកក្នុងមួយឡូតិ៍ លែងជាកម្មវត្ថុនៃវិវាទទៀតហើយ ពីព្រោះផលិតផលដែលមានលេខកូដ ១០០១៣ ត្រូវបានកម្មករផ្នែកផ្សេងធ្វើរួចអស់ហើយ ហើយផលិតផលនេះក៏លែងមានទៀតដែរ។ ក្រុមអាជ្ញាកណ្តាលក៏យល់ឃើញទៀតថា ចំណុចពិតរបស់វិវាទនេះ គឺនិយោជកមានគោលបំណងចង់ឱ្យកម្មករនិយោជិតផ្នែកប៉ះធ្វើការងារតាមការចាត់ចែងរបស់ក្រុមហ៊ុន និងយល់ព្រមទទួលយកតាមតម្លៃឡូតិ៍លេខកូដ ១០០១៣ ដែលក្រុមហ៊ុនបានកំណត់ឱ្យ។ ដូច្នេះ ក្រុមអាជ្ញាកណ្តាលនឹងធ្វើការពិចារណាលើការទាមទាររបស់និយោជក ដែលសុំឱ្យកម្មការិនីផ្នែកប៉ះគោរពតាមការចាត់ចែងរបស់ក្រុមហ៊ុន ដោយយល់ព្រមទទួលធ្វើលើឡូតិ៍១០០១៣ និងទទួលយកតាមតម្លៃឡូតិ៍ ដែលក្រុមហ៊ុនកំណត់ឱ្យវិញ។

<u>ចំណុចវិវាទ</u> ៖ ក្រុមហ៊ុនសុំឱ្យកម្មការនីផ្នែកប៉ះគោរពតាមការចាត់ចែងរបស់ក្រុមហ៊ុន ដោយយល់ព្រមធ្វើលើតម្លៃឡូតិ៍លេខកូដ ១០០១៣ ដែលក្រុមហ៊ុនបានដាក់ឱ្យធ្វើ

- នៅក្នុងក្រុមហ៊ុន ប្រេ្គត អននើរ ផេកស្តាយ ហ្វេកធើរី លីមីតធីត មានកម្មករនិយោជិត ដែលដេរស៊ីបុងនៅផ្នែកប៉ះចំនួនប្រមាណ ៩២ នាក់។
- ក្នុងមួយថ្ងៃ កម្មករនិយោជិត ដែលដេរស៊ីបុង ត្រូវបាននិយោជកឱ្យដេរឡូតិ៍ពិបាក និងមិនសូវពិបាក ។
- និយោជកបញ្ជាក់ថា ប្រហែលជាថ្ងៃទី៣ ឬទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ និយោជកបានដាក់នូវឡូតិ៍លេខ ១០០១៣ ឱ្យកម្មករនិយោជិតផ្នែកប៉ះធ្វើ ក្នុងតម្លៃមួយឡូតិ៍០.៣៥សេន ប៉ុន្តែកម្មករនិយោជិតនៅផ្នែកនេះមិនព្រមធ្វើទេ ដោយស្នើរសុំក្នុងតម្លៃមួយឡូតិ៍០.៦០សេន។ និយោជកមិនព្រមតម្លើងតាមការទាមទាររបស់កម្មករនិយោជិតទេ ហេតុនេះ ពួកគាត់មិនដេរលេខកូដ ១០០១៣ ទេ ។
- មកដល់បច្ចុប្បន្ននេះ ផ្នែកប៉ះមិនបានដេរនូវឡូតិ៍ដែលមានលេខកូដ ១០០១៣ នោះទេ ហើយឡូតិ៍នេះត្រូវ

បានកម្មករនិយោជិត ដែលនៅផ្នែកផ្សេងធ្វើវិញ។ សព្វថ្ងៃឡូតិ៍នេះមិនមានទៀតទេ។

- និយោជកបញ្ជាក់ថា កម្មករនិយោជិតគួរតែស្តាប់ការចាត់ចែងរបស់ក្រុមហ៊ុន ព្រោះផ្នែកពិនិត្យអាចដេរបាន ដោយពុំមានបញ្ហាអ្វីទាំងអស់ ដោយឡែកមានតែផ្នែកប៉ះប៉ុណ្ណោះ ដែលមិនចង់ដេរ ហើយទាមទារឱ្យមានការតម្លើងតម្លៃប៊ុង។ ចំពោះការតម្លើងតម្លៃប៊ុងនោះ គឺនិយោជកពុំមានលទ្ធភាព ក្នុងការផ្តល់ឱ្យទៅកម្មករនិយោជិតទេ។ និយោជកបានបញ្ជាក់ទៀតថា មានកម្មករនិយោជិតភាគតិចណាស់ ដែលមិនបានទទួលប្រាក់ឈ្នួលអប្បបរមា ដែលបានកំណត់ធានាដោយច្បាប់។ ចំពោះកម្មករនិយោជិត ដែលមិនបានទទួលប្រាក់ឈ្នួលអប្បបរមាទេនោះ និយោជកនឹងបន្ថែមឱ្យគ្រប់តែម្តង។
- ក្នុងករណីនេះ កម្មករនិយោជិតបានបញ្ជាក់ថា ខ្លួនមិនបានយល់ព្រមធ្វើតាមការចាត់ចែងរបស់ក្រុមហ៊ុននោះទេ ដោយខ្លួនយល់ឃើញថា តម្លៃប៊ុងលេខកូដ ១០០១៣ ដែលក្រុមហ៊ុនកំណត់តម្លៃប៊ុងនោះ គឺមានតម្លៃទាប ដែលកម្មករនិយោជិតធ្វើការដេរស៊ីប៊ុងភាគច្រើនពុំអាចទទួលបានប្រាក់ឈ្នួលអប្បបរមាទេ ព្រោះដោយសារតម្លៃប៊ុង ដែលនិយោជកគិតជូននោះទាបពេក និងម្យ៉ាងទៀត ការដេរស៊ីប៊ុងនេះមានម៉ូដ ដែលត្រូវដេរពិបាកខ្លាំងណាស់។ ចំពោះអ្នកដែលមានជំនាញ គឺដេរបានតែមួយឡូតិ៍កន្លះ រឺ ពីរឡូតិ៍ប៉ុណ្ណោះក្នុងមួយថ្ងៃ ដែលបើគិតតាមអត្រាចំនួនប្រាក់ ដែលទទួលបានក្នុងមួយថ្ងៃ ហើយសរុបជាខែ គឺទាបជាងប្រាក់ឈ្នួលអប្បបរមា។
- កម្មករនិយោជិតយល់ឃើញថា ការដេរមិនបានគ្រប់ប្រាក់ឈ្នួលអប្បបរមានេះ គឺ នៅពេលដែលខ្លួនដេរតែឡូតិ៍ ដែលមានលេខកូដ ១០០១៣ មួយតែប៉ុណ្ណោះ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឱ្យភាគីដាក់ភស្តុតាងមកត្រឹមថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១។
- និយោជកបានដាក់ភស្តុតាងមកបង្ហាញក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១។ តាមរយៈតារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិត រួមទាំងផ្នែកប៉ះ ក្នុងខែវិច្ឆិកា ដែលមិនបានដេរលើលេខកូដ ១០០១៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានកម្មករនិយោជិតសរុប៨៤នាក់ក្នុងផ្នែកប៉ះ ហើយមានកម្មករនិយោជិត៣៩នាក់ ដែលដេរបានក្រោមប្រាក់ឈ្នួលអប្បបរមា និងមានកម្មករនិយោជិត ៤៥ នាក់ ដែលដេរបានលើប្រាក់ឈ្នួលអប្បបរមា ដោយប្រាក់ឈ្នួលនេះ គឺមិនមានការដេរលើលេខកូដ ១០០១៣៕

## ហេតុផលនៃសេចក្តីសម្រេច៖

<u>ចំណុចវិវាទ</u> ៖ ក្រុមហ៊ុនសុំឱ្យកម្មការនីផ្នែកប៉ះគោរពតាមការចាត់ចែងរបស់ក្រុមហ៊ុន ដោយយល់ព្រមធ្វើលើតម្លៃឡូតិ៍លេខកូដ ១០០១៣ ដែលក្រុមហ៊ុនបានដាក់ឱ្យធ្វើ

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ រឺទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ

ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ ”។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥ និងលេខ ១៣/១១-ហ្វូលកាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងខាងលើដែរ ពោលគឺវិវាទអំពីសិទ្ធិ ជាវិវាទទាក់ទងនឹងសិទ្ធិ ដោយសារការទាមទារនេះជាការទាមទារទាក់ទងនឹងសិទ្ធិចាត់ចែង និងគ្រប់គ្រងរបស់និយោជក និងមានការពាក់ព័ន្ធនឹងច្បាប់ស្តីពីការងារ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា ដូចខាងក្រោម ៖

ក្នុងករណីនេះ កម្មករនិយោជិតផ្នែកប៉ះមិនព្រមធ្វើតាមការចាត់តាំងរបស់ក្រុមហ៊ុន នៅថ្ងៃទី៣ ឬ ៤ ខែវិច្ឆិកា ឆ្នាំ២០១១ ពាក់ព័ន្ធនឹងឡូតិ៍លេខ ១០០១៣ ដោយសារតែក្រុមហ៊ុនមិនព្រមតម្លើងតម្លៃមួយឡូតិ៍ដល់ ០.៦០ សេន តាមការស្នើសុំរបស់ខ្លួន។ ហេតុនេះហើយនិយោជកក៏យកលេខកូដ ១០០១៣ ទៅឱ្យផ្នែកផ្សេងធ្វើវិញ ហើយក៏បានដាក់ពាក្យបណ្តឹងទាក់ទងនឹងការប្រើសិទ្ធិចាត់ចែងរបស់ខ្លួនលើករណីនេះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានសិទ្ធិចាត់ចែងចំពោះការដាក់ការងារលើប៉ុងនីមួយៗឱ្យកម្មករនិយោជិតធ្វើដែរ រឺទេ ហើយការធ្វើឡើងនេះមានលក្ខណៈស្របច្បាប់ និងសមហេតុសមផល រឺទេ?

មាត្រា២ កថាខ័ណ្ឌ២ នៃច្បាប់ស្តីពីការងារចែងថា *“សហគ្រាសនីមួយៗ អាចមានគ្រឹះស្ថានច្រើន ហើយគ្រឹះស្ថាននីមួយៗនោះ មានប្រើមនុស្សមួយក្រុមធ្វើការរួមគ្នាក្នុងទីកន្លែងណាមួយជាប្រាកដ ដូចជាក្នុងរោងចក្រ រោងជាង ការដ្ឋាន ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក”* ។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា មាត្រា២ នៃច្បាប់ស្តីពីការងារនេះមានន័យថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ឱ្យតែសិទ្ធិនេះមានលក្ខណៈស្របច្បាប់ និងសមហេតុសមផល (សូមមើលសេចក្តីបង្គាប់លេខ ៥៤/០៧-យ៉ុងវ៉ាទី១ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី៩, លេខ ១១៦/០៧-ហ្វ្រេស សាន់ ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ២, លេខ ៤៧/០៨-ហ្វ្រែន ចិច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ២ និងលេខ ៥៣/០៩-តាក ហ្វាត ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី ២)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ស្របទៅនឹងសំណុំរឿងមុនដែរថា ការចាត់ចែងដាក់ការងារឱ្យកម្មករនិយោជិតធ្វើ គឺ និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រង ដើម្បីឱ្យដំណើរការក្នុងក្រុមហ៊ុនប្រព្រឹត្តទៅបានល្អ សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិក្នុងការចាត់ចែងការងារឱ្យកម្មករនិយោជិតធ្វើផងដែរ។ តាមអង្គហេតុនេះនិយោជកបានដាក់នូវឡូតិ៍លេខ ១០០១៣ ឱ្យកម្មករនិយោជិតផ្នែកប៉ះធ្វើក្នុងតម្លៃមួយឡូតិ៍ ០.៣៥ សេន។ ប៉ុន្តែកម្មករនិយោជិតផ្នែកប៉ះមិនព្រមធ្វើនោះទេ និងទាមទារឱ្យតំឡើងតម្លៃឡូតិ៍រហូតដល់ ០.៦០ សេន ដោយកម្មករនិយោជិតយល់ឃើញថា បើដេរលើឡូតិ៍នេះតែមួយ គឺកម្មករនិយោជិតមិនអាចដេរបានប្រាក់ឈ្នួលអប្បបរមានោះទេ។

តាមរយៈភស្តុតាង ដែលក្រុមហ៊ុនដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ គឺតារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្នែកប៉ះ ក្នុងខែវិច្ឆិកា ដែលមិនបានដេរលើលេខកូដ ១០០១៣ គឺនៅតែមាន

កម្មករនិយោជិត ដែលដេរបានលើសប្រាក់ឈ្នួលអប្បបរមា ដោយក្នុងនោះមានកម្មករនិយោជិត៤៥នាក់ ។ ហេតុនេះ ប្រសិនបើកម្មកនិយោជិតព្រមធ្វើតាមការចាត់ចែងរបស់ក្រុមហ៊ុនដេរលើលេខកូដ ១០០១៣ កម្មករនិយោជិតគឺអាច ទទួលបានលើសប្រាក់ឈ្នួលអប្បបរមា។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកមិនឃើញថា ការចាត់ចែងនេះមាន ការប៉ះពាល់ដល់ប្រាក់ឈ្នួលអប្បរមារបស់កម្មករនិយោជិតផ្នែកប៉ះ ដែលបានកំណត់ដោយច្បាប់នោះឡើយ។

មួយវិញទៀត ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ទោះបីមានការតវ៉ាពីតម្លៃបុង កម្មករនិយោជិតមិន អាចយកលេសមិនគោរពតាមការចាត់ចែងរបស់ក្រុមហ៊ុននោះទេ ពីព្រោះមាត្រា ៦៩ កថាខ័ណ្ឌទី ១ នៃច្បាប់ស្ដីពី ការងារបានចែងថា *"នៅក្នុងក្របខ័ណ្ឌនៃកិច្ចសន្យា កម្មករនិយោជិតត្រូវបញ្ចេញគ្រប់សកម្មភាពវិជ្ជាជីវៈរបស់ខ្លួន ដល់សហគ្រាស។ ជាអាទិ៍ កម្មករនិយោជិតត្រូវធ្វើការ ដែលគេជួលឱ្យធ្វើ ហើយអនុវត្តការងារនោះ ដោយខ្លួនឯង និងដោយយកចិត្តទុកដាក់"*។

ក្នុងសំណុំរឿងលេខ ៣៩/១១-អិម វ៉េ (សាខាទី១) ហេតុផលនៃសេចក្ដីសម្រេច ចំណុចវិវាទទី ១ និង ៤ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបកស្រាយមាត្រា ៦៩ កថាខ័ណ្ឌទី ១ នៃច្បាប់ស្ដីពីការងារថា "ការតវ៉ាពីរឿងតម្លៃ ឡូតិ៍ មិនបានហាមឃាត់កម្មកនិយោជិតមិនអាចធ្វើការលើ PN ១០៨-១០២ ដែលមានទំនាស់នោះទេ ពោលគឺ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតត្រូវធ្វើការលើការងារដែលនិយោជកដាក់ឱ្យ"។

*បន្ថែមពីលើនេះទៀត* តាមរយៈបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនត្រង់ប្រការ ២ ចំណុច ២ បានចែងថា *"កម្មករនិយោជិតគ្រប់រូប ត្រូវគោរពពេលម៉ោងធ្វើការ ឱ្យបានទៀងទាត់ អនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទបញ្ជា និងការ ចាត់តាំងរបស់ក្រុមហ៊ុន តាមមុខសញ្ញានិមួយៗដែលបានកំណត់"*។

ហេតុនេះ ការតវ៉ាដោយមិនព្រមដេរលើឡូតិ៍លេខ ១០០១៣ គឺជាការមិនត្រឹមត្រូវនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មករនិយោជិតត្រូវគោរពតាមការចាត់ចែងរបស់ក្រុមហ៊ុន។ ក៏ ប៉ុន្តែនៅក្នុងសំណុំរឿងនេះ ចំណុចវិវាទ គឺនិយោជកចង់ឱ្យកម្មករនិយោជិតគោរពតាមការចាត់ចែង ដោយដេរលើ លេខកូដ ១០០១៣ ដែលមកដល់បច្ចុប្បន្ន គឺមិនមានឡូតិ៍នេះនៅក្នុងសង្វាក់ផលិតកម្មទៀតនោះទេ។ ហេតុនេះ ក្រុម ប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា កម្មវត្ថុនៃវិវាទ គឺលែងមានទៀតហើយ ម្យ៉ាងទៀត ត្រូវបានកម្មករនិយោជិត ផ្នែកផ្សេងដេរអស់ហើយ។

សរុបសេចក្ដីមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបដិសេធការទាមទាររបស់និយោជក ដោយឱ្យកម្មករនិយោជិត គោរពតាមការចាត់ចែងដោយធ្វើលើឡូតិ៍លេខ ១០០១៣ ដែលបច្ចុប្បន្ននេះ គឺមិនមានទៀតនោះទេ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា អាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ដូចតទៅ៖

## **សម្រេច និង បង្គាប់**

ចំណុចវិវាទ៖

- បង្គាប់ឱ្យកម្មករនិយោជិតគោរពតាមការចាត់ចែងរបស់និយោជក ក្នុងករណីដែលការចាត់ចែងនោះ មិនប៉ះពាល់ដល់ប្រាក់ឈ្នួលអប្បរមា ដែលបានកំណត់ដោយច្បាប់។

- បដិសេធការទាមទាររបស់និយោជក ដែលតម្រូវឱ្យកម្មករនិយោជិតផ្អែកប៉ះ ដេរលើឡូតិ៍លេខ ១០០១៣ ខណៈដែលមកដល់បច្ចុប្បន្ននេះ ឡូតិ៍លេខ ១០០១៣ នេះ មិនមានក្នុងសង្វាក់ផលិតកម្មទៀតនោះ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះ ចេញទៅ ដោយភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់នេះ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា: ----------------------------------------